# របាយការណ៍
# ពីទីតាំងសម្លាប់ពីរៈ ស៊ឹងអមលាំង និងអ្នកតាអារក្សកាចន៍
# ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

ដោយៈ ដេង ពង្សរ៉ាសី

កាលពីថ្ងៃទី១៥ ខែសីហាឆ្នាំ២០០១ ក្រុមស្រាវជ្រាវផ្ទៃដែនទីរណ្ដៅសាកសពនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅកាន់ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺភ្លាមៗបន្ទាប់ពីបានទទួលពត៌មានពីក្រុមស្រាវជ្រាវប្រវត្តិរូបអតីតកម្មាភិបាលខ្មែរក្រហមមកថា នៅឃុំអមលាំងមានមន្ទីរឃុំឃាំងមួយកន្លែងដែលគ្រប់គ្រងដោយសមមិត្ត ឌុច និងមានទីតាំងសម្លាប់មនុស្សចំនួនពីរកន្លែងទៀត ។ ការធ្វើដំណើរត្រូវចំណាយរយៈពេលជាង៣ម៉ោងឆ្លងកាត់ផ្លូវដ៏លំបាកក្នុងចម្ងាយដីប្រហែលជាង៤០គីឡូពីទីរួមខេត្តកំពង់ស្ពឺ ។

## ឃុំអមលាំង

ថ្វីត្បិតតែមានផ្លូវលំបាកក្នុងការធ្វើដំណើរក៏ពិតមែន ប៉ុន្តែស្ថានភាពរស់នៅរបស់ប្រជាជនគ្មានអ្វីចោទជា បញ្ហាខាងជីវភាពប៉ុន្មានទេ ។ តាមសម្ដីរបស់អ្នកស្រីមេឃុំថា គ្មានអ្វីធំដុំចោទពីបញ្ហាជីវភាពនិងសន្តិសុខឡើយ ព្រោះលែងមានខ្មែរក្រហមទៀតហើយ ។ ឯការចុះទៅធ្វើការនៅឃុំនេះ ក្រុមយើងមិនមានបញ្ហាកង្វល់បន្តិចពីបញ្ហាខាងលើនេះដែរ ។

## ទីតាំងសម្លាប់ស៊ឹងអមលាំង លេខកូតភូមិសាស្ត្រៈ ០៥០៨០៣

ក្រុមស្រាវជ្រាវបានធ្វើដំណើរចាកចេញប្រហែល៣គីឡូម៉ែត្រពីសាលាឃុំអមលាំងឆ្ពោះទៅកាន់ទីតាំងសម្លាប់ផ្ទាល់ដែលស្ថិតនៅក្នុងភូមិថ្នល់បំបែកតាមផ្លូវក្រហែងក្រហូង និងដក់ទឹកមួយខ្សែ ។ ការសម្ភាសន៍សាក្សីបានប្រព្រឹត្តិទៅនៅនឹងទីតាំងផ្ទាល់តែម្ដង រួមជាមួយការកំណត់ទីតាំងភូមិសាស្ត្រតាមផ្កាយរណបតាមរយៈម៉ាស៊ីនកត់ត្រាទីតាំងភូមិសាស្ត្រពិភពលោក ។ ម៉ាស៊ីនបានកំណត់នូវរយៈទទឹងE 104º20'11:56"និងរយៈកំពស់ E 11º 48' 33:31" ។ ទីតាំងសម្លាប់នេះស្ថិតនៅចម្ងាយប្រហែល៥០០ម៉ែត្រពីភូមិថ្នល់បំបែក ដោយឆ្លងកាត់ស៊ឹងចំនួនពីរគឺស៊ឹងចាស់ និងស៊ឹងអមលាំង ។ ស៊ឹងទាំងពីរមានចម្ងាយប្រហែល១០០ម៉ែត្រពីគ្នាប៉ុណ្ណោះ ប៉ុន្តែការធ្វើដំណើរដោយថ្មើរជើងពិតជាមិនងាយស្រួលប៉ុន្មានឡើយ ។ លោកអ៊ំ អន ហន អាយុ៥៥ឆ្នាំ ជាប្រជាជនរស់នៅភូមិតាកោង ឃុំអមលាំងបានរៀបរាប់ប្រាប់ក្រុមស្រាវជ្រាវយើងអំពីរឿងរ៉ាវដែលបានកើតឡើងនៅលើដីទួលនៃស៊ឹងអមលាំងដោយគ្មានលាក់លៀមថា ដីទួលនេះបានកប់សាកសពជាទាហានភូមិភាគបូព៌ាអស់ចំនួនរាប់រយនាក់កាលពីដើមឆ្នាំ១៩៧៩ ។ អតីតទាហានជនរងគ្រោះទាំងនោះ ត្រូវបានលោក

អន ហានលើកមកនិយាយប្រាប់ថា ជាឈ្លើយសឹកទាហានដែលចាប់បានបន្ទាប់ពីចាប់មេធំឈ្មោះ **សោភឹម** និង**ចន្ទ័ចក្រី** រួចមក ។ កូនទាហានទាំងអស់ត្រូវបានគេណ្ហឲ្យមកធ្វើប្រលានយន្តហោះនៅកំពង់ឆ្នាំងនាចុងឆ្នាំ១៩៧៨ក្រោមការក្តោបក្តាប់របស់ទាហានខាងភូមិភាគបស្ចិម ។ ដោយមិនទុកចិត្តនិងស្ថិតក្រោមការរំសាយនៃទាហានភូមិភាគបូព៌ា ពួកខាងបស្ចិមបានបញ្ជូនទាហានភូមិភាគបូព៌ាដែលចាប់បានឲ្យមកធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំងមកសម្លាប់ចោលនៅលើដីទួលអមលាំងនេះ និងខ្លះទៀតបានបញ្ជូនទៅសម្លាប់នៅកន្លែងផ្សេងៗនាទឹកដីអមលាំងដូចគ្នា ។ លោកអ៊ឹបានបន្តថាទាហានខាងបូព៌ាដែលមានសម្លៀកបំពាក់ពណ៌ខៀវ(ត្រួយចេក) ម្នាក់ៗមានទឹកមុខស្រងូតស្រងាត់ គ្មានលទ្ធភាពនឹងតដៃ ព្រោះគ្មានកាំភ្លើងនៅជាប់នឹងខ្លួន ហើយត្រូវបង្ខំចិត្តធ្វើតាមបញ្ហាដែលដាក់ចុះ ។ សោភឹមបានធ្វើអត្តឃាតនៅឆ្នាំ១៩៧៨ព្រោះមិនអាចរើខ្លួនរួចពីការចោទប្រកាន់ថាក្បត់ ចន្ទ័ចក្រី ត្រូវបានកម្ទេចនៅឆ្នាំ១៩៧៨ពីមូលហេតុក្បត់ដូចគ្នា ។ ឯកូនទាហានរបស់គាត់ទាំងប៉ុន្មានត្រូវបានបោសសម្អាតតាមក្រោយនៅដើមឆ្នាំ១៩៧៩ដោយទាហានភូមិភាគបស្ចិម ។ ការដឹកកូនទាហានភូមិភាគបូព៌ាមកសម្លាប់ត្រូវបានដឹកជាក្បួនឡានធំៗឆ្លងកាត់តាមឃុំត្រាវពន្លក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងចូលមកតាមព្រំប្រទល់ខេត្តទាំងពីរគឺខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺឆ្ពោះមកកាន់ទឹកដីឃុំអមលាំង ស្រុកថ្ពង ហើយបានសម្រេចកម្ទេចគ្មាននរណាម្នាក់នៅមានជីវិតឡើយ ។ មានមូលហេតុច្បាស់លាស់មួយ ហើយត្រូវបានលោកអ៊ឹលើកមកនិយាយថា« គេខ្លាចពួកហ្នឹង(បូព៌ា) បះបោល ទើបគេយកពួកហ្នឹងមៅសម្លាប់ ប៉ុន្តែយកតែពួកបូព៌ាទេ» ។ លោកអ៊ឹ ហាន បាននិយាយបន្តថា ទាហានជនរងគ្រោះទាំងអស់ត្រូវបានបញ្ឆោតថាឲ្យទៅជួយវាយខ្មាំងយួន ហើយតម្រូវឲ្យរៀបចំសាក់កាដូឡើងឡានជាបន្ទាន់ ។ តែក្នុងរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ វាសនាទាហានទាំងនោះត្រូវបានចងទាំងខ្សែៗរុញទំលាក់ពីលើឡានបណ្តើរយកទៅវ៉ៃចោលដោយគ្មានក្តីមេត្តាដល់បក្សពួកតែមួយជាមួយគ្នាកាលពីប៉ុន្មានឆ្នាំមុនឡើយ ។ នៅលើដីទួលនៃស៊ឹងអមលាំងប្រហែលជា៣០ម៉ែត្របួនជ្រុងត្រូវបានជីករណ្តៅចំនួន៤សម្រាប់ដាក់សាកសព ហើយត្រូវបានលុបទៅវិញភ្លាមបន្ទាប់ពីសម្លាប់រួច ។លោកអ៊ឹបញ្ជាក់ថា គ្មានការវ៉ៃសម្លាប់តែមួយកន្លែងទេ គឺមានច្រើនកន្លែងទៀតក្នុងឃុំអមលាំង ។ ដាក់ស្តែងនៅខាងក្រោយផ្ទះរបស់គាត់ដែលមានចម្ងាយប្រហែលជាជាងមួយគីឡូម៉ែត្រមានរណ្តៅជាច្រើនទៀត ដែលពួកខ្មែរក្រហមបានសម្លាប់ពួកបូព៌ាដូចគ្នាបន្ទាប់ពីសម្រេចផែនការលើទួលស៊ឹងអមលាំងរួច ។ មូលហេតុនៃការផ្លាស់ប្តូរកន្លែងសម្លាប់ ត្រូវបានលោកអ៊ឹ ហាន រាយការណ៍ប្រាប់ថា ដោយខ្លាចពួកទាហានរំដោះ និងទាហានវៀតណាមចូលមកទាន់ ។ ការសម្លាប់ត្រូវបានលាក់ការណ៍សម្ងាត់ ។ ប្រជាជនត្រូវហាមឃាត់មិនឲ្យចូលក្នុងតំបន់ហាមឃាត់នេះ ។ ដំបង ត្បូងចប និង គល់ភ្លៃជាឧបករណ៍សម្លាប់ដ៏សំខាន់នាពេលនោះ ។ ក្រោយការសម្លាប់ឧបរណ៍ទាំងនេះត្រូវបោះគរនៅលើរណ្តៅដែលលប់ដីរួច ។ នៅខែ២ ១៩៧៩គឺប្រហែលកន្លះខែប៉ុណ្ណឹង

នៃព្រឹត្តិការណ៍សម្លាប់មនុស្សជាទាហានភូមិភាគបូព៌ា កងទ័ពវៀតណាម និង កងទ័ពរណសិរ្សរំដោះជាតិបានចូលកាន់កាប់នៅអមលាំង ។ កងទ័ពខ្មែរក្រហមទាំងអស់ត្រូវបង្ខំចិត្តភាសខ្លួនទៅ រស់នៅតំបន់ឆ្ងាយដាច់ស្រយាលពីភូមិប្រជាជន ។ ប៉ុន្តែការសម្លាប់មនុស្សដែលជាទាហានភូមិភាគបូព៌ាបានសម្រេចផែនការរួចទៅហើយ ។ លោកពូ កង យឿន អាយុ៥៨ឆ្នាំ ជាប្រជាជនរស់នៅភូមិថ្នល់បំបែក ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺបានប្រាប់ថា គាត់ធ្វើជាជាងដែកក្នុងសហករណ៍ភូមិថ្នល់បំបែក ឃុំអមលាំងកាលពីអំឡុងឆ្នាំ ១៩៧០ដល់១៩៧៥ ។ ចាប់ពីឆ្នាំ១៩៧៦ដល់១៩៧៩គាត់មិនបាននៅក្នុងភូមិថ្នល់បែកទេ គឺត្រូវជម្លៀសចេញ ប៉ុន្តែស្ថិតនៅក្នុងស្រុកថ្ពងដែរ ។ ចំពោះហេតុការណ៍នៅលើទួលនៃស្ទឹងអមលាំង លោកពូបាននិយាយថាគាត់មិនបានឃើញផ្ទាល់ភ្នែកទេ ប៉ុន្តែគាត់បានទៅឃើញប្រជាជនរួមនឹងមន្ត្រីថ្នាក់ខេត្តមួយចំនួនបានទៅគាស់រណ្តៅទាំង៤ខាងលើនេះនៅឆ្នាំ១៩៨១-៨២ ។ លោកពូបាននិយាយពីការគាស់រណ្តៅសាកសពថាការជីកនេះគឺមិនមែនរកមាសទេ គឺជីកដើម្បីយកក្បាលទៅដាក់តំរៀបនៅឃុំ ហើយក្រោយមកយកទៅតម្កល់ទុកនៅវត្តឫស្សីសំ ។ គាត់បានបន្តថា សាកសពដែលគាស់មកនេះ គឺសុទ្ធសឹងតែទាហានភូមិភាគបូព៌ាដែលបានចោទថាក្បត់ ។ លោកអ៊ឹហម អួន អាយុ៦២ឆ្នាំ បាននិយាយខ្លាំងៗថា នៅលើដីទួលនៃស្ទឹងអមលាំងនេះពិតជាកន្លែងសម្លាប់កាលពីឆ្នាំ១៩៧៩ពិតប្រាកដ ព្រោះបានទៅមើលការគាស់រណ្តៅទាំងនោះផ្ទាល់ ។ លោកអ៊ឹបានប្រាប់ថាមានរណ្តៅធំៗដែលមានទទឹងប្រហែល៣ម៉ែត្រនិងបណ្តោយ៥ម៉ែត្រចំនួន៤រណ្តៅនៅជាប់ៗគ្នា ។ រណ្តៅទាំងបួននេះត្រូវបានសន្និដ្ឋាននូវចំនួនសាកសពសរុបចំនួនជាង១០០នាក់ ។ បច្ចុប្បន្នរណ្តៅទាំង៤នោះនៅមានស្លាកស្នាមជ្រៅៗ ហើយមានរុក្ខជាតិតូចធំដុះពោរពាសពេញមាត់រណ្តៅ ។

## ទីតាំងសម្លាប់អ្នកតាអារក្សកាចន្ទ័ លេខកូតភូមិសាស្ត្រ:០៥០៨០៤

ទួលអ្នកតាអារក្សកាចន្ទ័ ជាទួលដែលប្រជាជនក្នុងភូមិកុមារមាស ឃុំអមលាំងនិយមហៅតាំងពីដើមមក ដីទួលនេះស្ថិតនៅចម្ងាយប្រហែលជាងមួយគីឡូម៉ែត្រពីភូមិប្រជាជនប៉ែកខាងជើង ។ កាលពីជំនាន់ប៉ុលពត ទួលនេះជាកន្លែងធ្វើជីប្រចាំសហករណ៍ ហើយនៅដើមឆ្នាំ១៩៧៩ បានក្លាយជាកន្លែងសម្លាប់កប់សាកសពទាហានភូមិភាគបូព៌ា ។ បច្ចុប្បន្នពុំសូវមានប្រជាជនដើរឆ្លងកាត់ឡើយ ព្រោះជាដីមិនមែនសម្រាប់បង្កបង្កើនផល និងធ្វើចំការ ប៉ុន្តែជាដីព្រៃដែលមានសុទ្ធតែដើមឈើតូចធំ និងស្មៅប៉ុណ្ណោះ ។ ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរទៅដល់ទួលអ្នកតាអារក្សកាចន្ទ័ដោយថ្មើរជើងឆ្លងកាត់ស្ទឹងអមលាំង ដែលកាលពីដើមហៅថាស្ទឹងក្រាំងពន្លៃ ។ ស្ទឹងមួយខ្សែនេះ បានធ្វើឲ្យប្រជាជនដែលមានស្រែចម្ការនៅក្បែរៗមាត់ស្ទឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្កបង្កើនផល ស្រោចដំណាំ បូករួមទាំងការប្រើប្រាស់ផ្សេងៗ និងផ្ងូតសម្អាតកាយ ។ ពេលដែល

ក្រុមស្រាវជ្រាវយើងដើរឆ្លងកាត់ស៊ីង  ចំពេលដែលមានភ្លៀងធ្លាក់ចុះមួយមេយ៉ាងធំ ។  ទឹកស៊ីងហូរត្របាញ់ឆ្ពោះទៅទិសខាងកើតយ៉ាងវែងអន្ទាយគ្មានទិសដៅ ។  ខោអាវទទឹកជោក  ខ្លួនរងារចំប្រប់ស្ពាយកាបូបដាក់សម្ភារៈ  ដើរតម្រង់ទៅរកទិសដៅ ។ សភាពបែបនេះធ្វើឲ្យខ្ញុំនឹកឃើញហ្វូងមនុស្សទាំងឡាយក្នុងសម្លៀកបំពាក់ខ្មៅដើរលើចប  រែកបង្គីរដើរឆ្ពោះទៅរកការដ្ឋានទាំងគ្មានកម្លាំងកំហែង  ខ្លះដួលដោយកម្លាំងខ្យល់បក់  ខ្លះដួលដោយជើងទាក់នឹងស្មៅ  និងមានខ្លះទៀតដួលស្លាប់ដោយការហេវហត់ហួសប្រមាណ ។  ម្យ៉ាងវិញទៀតការធ្វើដំណើរទៅកាន់កន្លែងសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហម  ពិតជាធ្វើឲ្យខ្ញុំមានអារម្មណ៍ស្រងេះស្រងោចនឹកដល់បងប្រុសម្នាក់ដែលបានស្លាប់ដោយជម្ងឺនៅក្រោមតំណក់ទឹកភ្លៀងនាខែវស្សាក្នុងរោងផ្ទះធ្លាយមួយ  នាស្រុកមោង(មោងឫស្សី)  ខេត្តបាត់ដំបងនិងបូករួមទាំងគ្មានថ្នាំព្យាបាលផង ។

ក្រុមស្រាវជ្រាវបានធ្វើការសម្ភាសន៍ជាមួយមនុស្សពីរនាក់ដែល  សុទ្ធតែជាអ្នកដឹងរឿងរ៉ាវច្បាស់កាលពីជំនាន់នោះ ។  ការប្រើប្រាស់ម៉ាស៊ីនកត់ត្រាតាមផ្កាយរណប  ត្រូវនៅរង់ចាំភ្លៀងរាំង ។  នៅវេលាម៉ោង ២ៈ៤៥នាទី  មេឃចាប់ផ្តើមស្រឡះ  ភាពងងឹតក្នុងព្រៃចាប់ផ្តើមមានពន្លឺឡើងវិញ  ធ្វើឲ្យក្រុមយើងដែលមានអារម្មណ៍ភយ័ខ្លាចកាលពីមុនត្រូវរលាយបាត់អស់  ហើយចាប់ផ្តើមធ្វើការងាររៀងៗខ្លួន ។  មិនយូរប៉ុន្មានម៉ាស៊ីនបានកំណត់នូវរយៈទទឹង  E  104º21'17:84" និងរយៈកំពស់  E  11º  48'  06:39" នៃទីតាំងអ្នកតាអារក្សកាចន្ទ័ ។  ជាក់ស្តែងនៅមានស្លាកស្នាមរណ្តៅជាច្រើនមានទំហំធំៗ  ដែលមានទឹកដក់ពេញៗរណ្តៅ ។

លោកពូឡុង  វង់  អាយុ៤៨ឆ្នាំ  បច្ចុប្បន្នរស់នៅភូមិកុមាររមាស  ឃុំអមលាំង  ស្រុកថ្ពងបានរៀបរាប់ថា កាលពីឆ្នាំ១៩៧៥  លោកពូបានជម្លៀសទៅនៅឃុំត្រពាំងជោរ ។  ហើយក្រោយមកគាត់បានមករស់នៅភូមិកំណើតវិញ ។  ក្រោយពីបានមករស់នៅភូមិកំណើតលោកពូបានជាប់នៅក្នុងគុកមួយ  ហៅថា “មន្ទីរ៧៣” ។  តាមសម្តីរបស់គាត់ថាមន្ទីរនេះជាមន្ទីរសន្តិសុខរបស់ភូមិភាគបស្ចឹមដែលមានឈ្មោះ  **វី**  ជាប្រធានសន្តិសុខ  ហើយក៏ជាអនុប្រធានរបស់  **តាស៊ី**  ប្រធានភូមិភាគបស្ចឹមដែរ ។  លោកពូបានជាប់តែក្នុងរយៈពេលជាងមួយខែប៉ុណ្ណោះ ។  ការងាររបស់គាត់នៅក្នុងគុកគឺរែកដី ។  លោកពូនិយាយថា  ទោសរបស់គាត់មិនដល់ថ្នាក់ជាប់ទោសធ្ងន់ធ្ងរទេ  ហើយក៏មិនបានទៅជាប់ខ្នោះឃ្នាងដែរ ។  គ្រាន់តែបាត់មាន់មួយ  ធ្វើឲ្យគាត់ទទួលទណ្ឌកម្មរែកដីជាងមួយខែ ។  មន្ទីរសន្តិសុខនេះស្ថិតនៅជាប់នឹងភ្នំពីស  ហើយផ្លូវទៅកាន់ទីកន្លែងនោះពិបាកហើយស្ថិតនៅក្នុងព្រៃជ្រៅពីភូមិទៀត ។  សំណួរមួយចំនួនត្រូវបានចោទសួរគាត់ពីការសម្លាប់មនុស្សនៅទួលអ្នកតាអារក្សកាចន្ទ័កាលពីដើមឆ្នាំ១៩៧៩ ។  លោកពូបានឆ្លើយទាំងសភាពពេញចិត្តនឹងឆ្លើយតបនូវសំណួររបស់ក្រុមយើងយ៉ាងក្បោះក្បាយបញ្ជាក់ពីហេតុការណ៍កាលពេលនោះដូចតទៅៈ

នៅឆ្នាំ១៩៧៩  ប្រហែលជាដើមខែមករាមានការដឹកទាហានខាងភូមិភាគបូព៌ាទាំងឡានៗមកសម្លាប់នៅទួលអ្នកតាអារក្សកាចន្ទ័ដោយស្តុបទុកបណ្តោះអាសន្នក្នុងរយៈពេលខ្លីមួយប៉ុណ្ណោះ ។  ការស្តុបទុកនេះគឺភាគ

ច្រើនស្តុបទុកនៅមាត់ស្ទឹងក្រាំងពន្លៃ ហៅស្ទឹងអមលាំង ។ អ្នកទោសដែលបញ្ជូនមកស្ថិតក្នុងសភាពស្មោកស្មាំង ដៃជាប់ចំណង ។ ការបញ្ឆោតយកអ្នកទោសមកសម្លាប់ ជាវិធីសាស្ត្រមួយដែលពួកខ្មែរក្រហមចូលចិត្តប្រើ ញឹកញាប់ជាងគេនៅស្ទើរតែគ្រប់កន្លែងទូទាំងប្រទេស ។ ទាហានភូមិភាគបូព៌ាទាំងអស់ត្រូវបានបញ្ឆោតថាឲ្យទៅជួយវាយខ្មាំងយួន ប៉ុន្តែត្រូវចាញ់បោកគ្នាឯង ហើយត្រូវអស់ជីវិតនៅលើទឹកដីអមលាំងគ្មានសល់ ។ កាលនោះស្ទឹងក្រាំងពន្លៃនេះមិនអនុញ្ញាតិឲ្យប្រជាជនណាម្នាក់ទៅជិត ឬដួតទឹកបានឡើយ ។ ប្រសិនបើហ៊ានល្មើសនឹងបំរាមនេះនឹងត្រូវស្លាប់ភ្លាម ។ ការក្រឡេកភ្នែកមើលម្តងៗរបស់លោកពូ វង់ បានធ្វើឲ្យគាត់សន្និដ្ឋានភ្លាមថា មានទាហានខាងបស្ចឹម និងខាងបូព៌ា ។ លុះយូរៗទៅទើបដឹងថាអ្នកចាប់ដែលមានសម្លៀកបំពាក់ពណ៌ខ្មៅជាទាហានភូមិភាគបស្ចឹម ឯអ្នកដែលត្រូវបានចាប់ដែលមានសម្លៀកបំពាក់ពណ៌ត្រួយចេក ជាទាហានភូមិភាគបូព៌ា ។ ទាហានខាងបស្ចឹមត្រូវបានបែងចែកជាពីរផ្នែក មួយផ្នែកជាអ្នកដឹកជញ្ជូនមកស្តុបទុកបណ្តោះអាសន្ននៅមាត់ស្ទឹង និងមួយផ្នែកទៀតជាអ្នកបណ្តើរពីមាត់ស្ទឹងយកទៅសម្លាប់ចោលនៅទួលអ្នកតាអារក្សកាចន្ទ័ ។ ការបញ្ជូនមកសម្លាប់គឺមានជាហូរហែរ ។ រណ្តៅត្រូវបានជីកទុកមុនរួចជាស្រេច ។ ពេលបញ្ជូនជនរងគ្រោះមកភ្លាមគឺកម្ទេចភ្លាម ។ វិធីសម្លាប់គឺគ្មានអ្វីក្រៅពីដំបង និងត្បូងចបឡើយ ។ ឯកាំភ្លើងមិនត្រូវបានយកមកប្រើទេ ។ ក្រោយការសម្លាប់ ដំបង ត្បូងចប និងមែកឈើយ៉ាងច្រើនត្រូវបានបោះគ្របពីលើរណ្តៅ ។ លោកពូ វង់ បាននិយាយពីសាកសពក្នុងរណ្តៅថា មានរណ្តៅខ្លះ២០នាក់ រណ្តៅខ្លះ៣០នាក់ រណ្តៅខ្លះ៥០នាក់ ។ ឯចំនួនជនរងគ្រោះនៅទួលអ្នកតាអារក្សកាចន្ទ័វិញ លោកពូបានប៉ាន់ស្មានថាមានចំនួនរាប់រយនាក់ ។ ចំណែកចំនួនរណ្តៅវិញ លោកពូនិយាយថាមិនអាចរាប់បានទេ ព្រោះមានច្រើន ប៉ុន្តែរណ្តៅដែលក្រុមស្រាវជ្រាវយើងឃើញផ្ទាល់ភ្នែកមានរណ្តៅធំចំនួន៥រណ្តៅ ទំហំទទឹងប្រហែលពី៣-៥ម៉ែត្រ និងបណ្តោយប្រហែលពី៧-១០ម៉ែត្រ និងរណ្តៅតូចជាង១០ទៀត ។ ក្រោយឆ្នាំ១៩៨០ មានរណ្តៅខ្លះបានជីកយកលលាដ៏ក្បាលដាក់តម្កល់នៅវត្ត និងមានរណ្តៅខ្លះទៀតមិនត្រូវបានជីកទេ ដោយមូលហេតុមិនប្រាកដ ព្រោះកាលនោះមានអ្នកធ្វើការខាងសាលាខេត្ត និងស្រុកមួយចំនួនមកជីក ។ មីង ហាប់ ស្រីហៀង អាយុ៤២ឆ្នាំ បច្ចុប្បន្នជាប្រជាជនរស់នៅភូមិតាកោង ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺបានប្រាប់ថា ថ្ងៃមួយ(មិនចាំថ្ងៃខែឆ្នាំ) នៅពេលដែលកូនប្រុសរបស់គាត់ទៅឃ្វាលគោនៅលើទួលអ្នកតាអារក្សកាចន្ទ័ ក៏បានរើសឆ្អឹងសាកសពជាច្រើនយកមកលេងជាមួយមិត្តភក្រ័ ចៃដន្យក្មេងនោះបានក្រឡេកទៅឃើញគ្រាប់ភ្នែកកែវមួយនៅកប់ដីថើរៗ ។ កូនរបស់មីងបានទៅឆ្កឹះមកជូតដីចេញ ហើយឃើញដូចភ្នែកមនុស្ស ក្មេងម្នាក់នោះបានយកកែវភ្នែកម្ខាងនោះទៅឲ្យម្តាយរបស់វាទុក ។ រហូតមកដល់សព្វថ្ងៃ កែវភ្នែកនោះត្រូវបានរក្សារទុកយ៉ាងម៉ត់ចត់បំផុត ។

**សន្និដ្ឋាន**

ទីតាំងទាំងពីកន្លែងខាងលើនេះ ថ្វីត្បិតតែក្រុមយើងចុះទៅតែក្នុងរយៈពេលខ្លី ប៉ុន្តែយើងបានដឹងប្រាកដថាជនរងគ្រោះដែលបានស្លាប់នៅលើទីតាំងទាំងពីរនេះ សុទ្ធសឹងតែជាទាហានភូមិភាគបូព៌ាដែលត្រូវបានរំសាយចេញបន្ទាប់ពីមេខ្លោងធំពីរត្រូវធ្វើអត្តឃាដ និងសម្លាប់ពីបទថាក្បត់នឹងអង្គការ ។ កូនទាហានដែលនៅរស់ទាំងប៉ុន្មានត្រូវបញ្ជូនមកឲ្យធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ដោយមានទាហានខាងភូមិភាគបស្ចឹមជាអ្នកក្តោបក្តាប់ពីលើ ។ ចុងបញ្ចប់ជីវិតរបស់ទាហានទាំងនោះ បានបញ្ចប់ដូចមេកើយរបស់ខ្លួននៅដើមឆ្នាំ១៩៧៩ ដោយសារវៀងភ័វខ្លាចរអែងមានការបះបោលតបតវិញពីទាហានភូមិភាគបូព៌ា ។ រយៈពេលប្រហែលកន្លះខែក្រោយមកទាហានវៀតណាម និងទាហានរណសិរ្សរំដោះជាតិកម្ពុជាបានចូលទៅរំដោះបានស្រុកថ្ពងទាំងមូល ប៉ុន្តែការសម្លាប់របស់ខ្មែរក្រហមទៅលើទាហានភូមិភាគបូព៌ាបានបញ្ចប់ទៅហើយ ។ បច្ចុប្បន្នបានបន្សល់នូវស្លាក់ស្នាមជារណ្តៅធំៗ ក្រហេងក្រហូងស្ទើរតែពេញព្រៃនៃទឹកដីឃុំអមលាំង ។ ការសម្លាប់មនុស្ស ការធ្វើទារុណកម្មមនុស្ស និងការបោកបញ្ឆោតមនុស្ស ធ្វើឲ្យប្រជាជនភាគច្រើន ជាពិសេសនៅឃុំអមលាំងស្អប់ខ្ពើម និងប្រាថ្នាកើតជាតិណាៗកុំឲ្យជួបរបបដែលសម្លាប់មនុស្សដូចសត្វធាតុនេះទៀត ។ អ្នកមីង ហាក់ ស្រីហៀង លោកពូ ឡុង វង់ លោកអ៊ំ អន ហន លោកពូកង យឿន និងលោកតា ហម អួន សុទ្ធតែបាននិយាយ និងសច្ចារដូចៗគ្នាថា ផ្សងទៅមុខមិនឲ្យជួបរបបខ្មែរក្រហមទៀតទេ ព្រោះវេទនាណាស់ សម្លាប់មនុស្សចោលដោយគ្មានញញើតដៃ ។